The NGO Forum on Cambodia
Working Together for Positive Change

Cambodian Center for Human Rights

COMFREL

CLEC

CAMBODIANS FOR RESOURCE REVENUE TRANSPARENCY

<u>រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១៣</u>

# សេចក្តីប្រកាសព័ត៌មាន
# វេទិកាពិភាក្សាគោលនយោបាយ
# "ទស្សនៈរបស់គណបក្សនយោបាយស្តីពី បរិស្ថាន និងដីធ្លី ក្នុងប្រទេសកម្ពុជា"

វេទិកាពិភាក្សាគោលនយោបាយលើប្រធានបទ **"ទស្សនៈរបស់គណបក្សនយោបាយស្តីពី បរិស្ថាន និងដីធ្លីនៅកម្ពុជា"** នឹងរៀបចំឡើងនាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០១៣ នៅសណ្ឋាគារ ***មណ្ឌលគិរី*** ភូមិចំបក់ សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។

គោលបំណងនៃវេទិកានេះ គឺដើម្បីផ្តល់ឱកាសដល់គណបក្សនយោបាយសំខាន់ៗ បង្ហាញពីគោលនយោបាយនានារបស់ខ្លួន ស្តីពីបរិស្ថាន និងដីធ្លី មុនការមកដល់នៃការបោះឆ្នោតជាសកលនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៣ ខាងមុខនេះ ដើម្បីជានាឲ្យប្រជាពលរដ្ឋកម្ពុជា អង្គការសង្គមស៊ីវិល និង អាជ្ញាធរមូលដ្ឋាន បានទទួលព័ត៌មានគ្រប់គ្រាន់អំពីជំហររបស់គណបក្សទាំងនេះពាក់ព័ន្ធបញ្ហាសំខាន់ទាំងនោះ សម្រាប់ លើកទឹកចិត្តឲ្យមានការចូលរួមក្នុងការបោះឆ្នោតកាន់តែច្រើន។

ក្នុងវេទិកាដ៏មានសារៈសំខាន់នេះ តំណាងគណបក្សនយោបាយធំៗចំនួន៣ គឺគណបក្សប្រជាជនកម្ពុជា គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សសង្គ្រោះជាតិ ត្រូវបានអញ្ជើញចូលរួមដើម្បីបង្ហាញពីគោលនយោបាយរបស់គណបក្សពាក់ព័ន្ធបញ្ហាខាងលើ ដល់អ្នកចូលរួម។

អ្នកសារព័ត៌មានក៏ត្រូវបានអញ្ជើញអោយចូលរួមក្នុងវេទិកានេះផងដែរ។

<u>កាលបរិច្ឆេទ និងទីកន្លែង</u>

ព្រឹត្តិការណ៍: វេទិកាពិភាក្សាគោលនយោបាយលើប្រធានបទ "ទស្សនៈរបស់គណបក្សនយោបាយស្តីពីបរិស្ថាន និងដីធ្លី" រៀបចំឡើងដោយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

(ម.ស.ម.ក) មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍(ម.អ.ច.ស) អង្គការខុមហ្វ្រែល និងសម្ព័ន្ធ-ភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (ស៊ី.អា.អា.ធី)។

កាលបរិច្ឆេទ: ថ្ងៃពុធ ទី១៩ ខែមិថុនា ឆ្នាំ២០១៣ ម៉ោង ៧:៣០នាទីព្រឹក ដល់ ម៉ោង ៥:០០នាទីល្ងាច

ទីកន្លែង : សណ្ឋាគារ មណ្ឌលគីរី ភូមិចំបក់ សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី

អ្នកចូលរួម: ចំនួន ១២០នាក់ ដែលអញ្ជើញមកពីភ្នំពេញ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគីរី និងខេត្តមណ្ឌលគីរី

ព័ត៌មានបន្ថែមសូមទាក់ទង:

- លោក វណ្ណ សុផាត (ម.ស.ម.ក)
  ទូរស័ព្ទលេខ ០១២ ៩៤១ ២០៦
- លោក ផាន់ ស៊ីថាន (វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា)
  ទូរស័ព្ទលេខ ០៧៧ ៧១៧ ៧៩៧
- លោក សួន យុជ្យា (អង្គការខុមហ្វ្រែល)
  ទូរស័ព្ទលេខ ០៨៨ ៨១៤ ២៧៨៣
- លោក ហួន ជុនឌី (ម.អ.ច.ស)
  ទូរស័ព្ទលេខ ០១២ ៩៤២ ៣២៦
- លោកស្រី គឹម ណាតាសា (ស៊ី.អា.អា.ធី)
  ទូរស័ព្ទលេខ ០១២ ៥១៣ ៨០២